# ភាពស្លូតបូត និងឆន្ទៈរបស់គេនៅក្នុងការជឿ

អែលឌើរ ម៉ៃខល ធី រីងវូដ
នៃពួកចិតសិបនាក់

*ការរស់នៅតាមដំណឹងល្អគឺនាំមកនូវដួងចិត្តទន់ទាប ដើម្បីមានចិត្តស្លូតបូត ហើយមានឆន្ទៈជឿដល់ព្រះបន្ទូលរបស់ព្រះ ។*

កាលពីប៉ុន្មានខែកន្លងទៅ ខ្ញុំបានទាក់អារម្មណ៏ដដែលៗទៅលើវគ្គគម្ពីរមួយ ដែលមានកត់ត្រានៅក្នុងហេលេមិនជំពូក 6 ។ "ម្ល៉ោះហើយ យើងឃើញថា ព្រះអម្ចាស់ទ្រង់បានចាប់ផ្ដើមស្រោចព្រះវិញ្ញាណទ្រង់ ទៅលើពួកសាសន៏លេមិនដោយសារភាពស្លូតបូត និងឆន្ទៈរបស់គេ នៅក្នុងការជឿដល់ព្រះបន្ទូលរបស់ទ្រង់" (ហេលេមិន ខ 36) ។

នៅពេលខ្ញុំអានបទគម្ពីរនេះ អំឡុងពេលការសិក្សាផ្ទាល់ខ្លួនរបស់ខ្ញុំ វាបានប៉ះនឹងដួងចិត្តរបស់ខ្ញុំយ៉ាងជ្រាលជ្រៅ ហើយបណ្ដាលឱ្យខ្ញុំគិតអំពីវាជាច្រើនសប្ដាហ៏ ។ ខ្ញុំបានចាប់ផ្ដើមសួរសំណួរ តើខ្ញុំបានមានភាពស្លូតបូតដើម្បីជឿលើ ព្រះបន្ទូលរបស់ព្រះឬទេ ។ ហើយហេតុអ្វីបានជាមានងាយស្រួលសំរាប់ពួកសាសន៏លេមិនផ្លាស់ប្រែចិត្តជឿដូច្នេះ? តើអ្វីខ្លះបានកើតឡើងដែលបណ្ដាលឱ្យប្រជាជនមានភាពស្អប់ខ្ពើម ហើយមិនជឿលើភាពស្លូតបូត និងមានឆន្ទៈជឿលើព្រះបន្ទូលរបស់ព្រះ (សូមមើល នីហ្វៃទី 4 1:39)?

យើងបានដឹងអំពីបុព្វហេតុនៃការផ្លាស់ប្ដូរនេះ អំឡុងពេលឆ្នាំដ៏អស្ចារ្យបំផុតមួយ ។ អំឡុងពេលឆ្នាំទីហុកសិបពីរនៃរាជរបស់ចៅក្រម មានជនជាតិលេមិនចំនួន 8,000 នាក់នៅក្នុងសារ៉ាហិមឡា ត្រូវបានផ្លាស់ប្រែចិត្តជឿ នៅពេលនីហ្វៃ និងលីហៃបានបង្រៀនដោយអានុភាព និងសិទ្ធិអំណាច ហើយមានអ្វីៗដែលពួកគេគួរត្រូវបង្រៀន ដែលបានប្រទានដល់ពួកគេ (សូមមើល ហេលេមិន 5:18--19) ។ មនុស្សចំនួនបីរយនាក់ទៀតត្រូវបានផ្លាស់ប្រែចិត្តជឿ តាមរយៈបទពិសោធន៏ដ៏អព្ភូតហេតុមួយ ដែលពួកគេបានឮសម្លេង ដែលចាក់ទំលុះទៅដល់ព្រលឹងរបស់ពួកគេ (សូមមើល ហេលេមិន 5:30) ។ មនុស្សទាំង 300 នាក់នេះបានទៅដើម្បីសំលាប់នីហ្វៃ និងលីហៃ នៅពេលពួកគេអង្គុយនៅក្នុងគុក ប៉ុន្តែបានរកឃើញ ពួកគេកំពុងតែអធិស្ឋានទៅរកព្រះ នៅពេលអ័មីណាដាប់ ដែលជាអតីតសាសន៏នីហ្វៃ ហើយបានខ្វែងគំនិតទាស់នឹងសាសនាចក្របានចងចាំ និងដឹងថា ពួកគេគួរតែអធិស្ឋានរហូតដល់ពួកគេមានសេចក្ដីជំនឿទៅលើព្រះគ្រីស្ទ (សូមមើល ហេលេមិន 5:35--41) ។ សាសន៏លេមិនជាច្រើនទៀត ត្រូវបានផ្លាស់ប្រែចិត្តជឿតាមរយៈទីបន្ទាល់របស់ប្រជាជន 300 នាក់ នៅពេលពួកគេបានបំរើដល់ប្រជាជន ប្រកាសថាពួកគេបានមើលឃើញ និង បានស្ដាប់ឮ (សូមមើល ហេលេមិន 5:49--50) ។

ចុងឆ្នាំទីហុកសិបពីរ មាននូវសេចក្ដីថ្លែងនេះថា: "ការណ៏អស់ទាំងនេះបានកើតឡើង ហើយពួកសាសន៏លេមិនភាគច្រើន បានក្លាយទៅជាប្រជាជនសុចរិត" (ហេលេមិន 6:1) ។

គុណសម្បត្តិនៃការផ្លាស់ប្រែចិត្តជឿរបស់ពួកគេ បាននាំពួកសាសន៏លេមិនទាំងនេះ បោះចោលការស្អប់របស់ពួកគេ ចំពោះពួកសាសន៏នីហ្វៃ ហើយដាក់គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់ពួកគេចុះ (សូមមើល ហេលេមិន 5:51 ) ពួកគេបានរឹងប៉ឹង និងខ្ជាប់ខ្ជួននៅក្នុងសេចក្ដីជំនឿរបស់ពួកគេ (សូមមើលហេលេមិន 6:1) ។ ពួកគេរក្សាបទបញ្ញត្តិទាំងឡាយ ហើយដើរនៅក្នុង

សេចក្ដីជំនឿពិត និងសេចក្ដីស្មោះត្រង់ (សូមមើល ហេលេមិន 6:34)។ ហើយពួកគេបានរីកចំរើននៅក្នុងចំណេះដឹងរបស់ពួកគេអំពីព្រះ (សូម វែតសុន មើល ហេលេមិន 6:34)។

អ្វីដែលធ្វើឱ្យចាប់អារម្មណ៍បំផុតចំពោះខ្ញុំ គឺភាពស្លូតបូត និងឆន្ទៈរបស់ពួកគេ ដើម្បីជឿលើព្រះបន្ទូលរបស់ព្រះ។ ភាពស្លូតបូត និងឆន្ទៈដើម្បីជឿនេះ បាននាំឱ្យពួកគេមានព្រះវិញ្ញាណដ៏បរិបូរណ៍ ហើយបានជួយពួកគេឱ្យប្រកាន់ខ្ជាប់ នៅក្នុងសេចក្ដីជំនឿរហូតដល់ទីបញ្ចប់ (សូមមើល ហេលេមិន 15:5--9)។

គួរឱ្យសោកស្ដាយ នៅអំឡុងពេលដូចគ្នានេះ ពួកសាសន៍នីហ្វៃភាគច្រើនបានក្លាយទៅជារឹងទទឹង មិនប្រែចិត្ត ហើយអាក្រក់ក្រៃលែង (ហេលេមិន 6:2 សូមមើលផងដែរ ខទី 31--34)។ អ្វីដែលសាសន៍លេមិន កំពុងមានបទពិសោធន៍ វាផ្ទុយទៅ នឹងអ្វីដែលកំពុងតែកើតឡើងចំពោះពួកសាសន៍នីហ្វៃ។ ភាពរឹងរូសនៃចិត្តពួកគេបាននាំឱ្យព្រះវិញ្ញាណដកថយ(សូមមើល ហេលេមិន 6:35)ខណៈពេលដែលភាពទន់ភ្លន់នៃចិត្តរបស់ពួកសាសន៍លេមិន បាននាំមកនូវការចាក់ស្រោចនៃ ព្រះវិញ្ញាណ។

នៅពេលខ្ញុំបានពិចារណានូវអ្វីដែលបានបណ្ដាលឱ្យមានការផ្លាស់ប្ដូរដ៏ធំនេះ នៅក្នុងដួងចិត្តរបស់ពួកសាសន៍លេមិន ទាំងនេះ ខ្ញុំបានដឹងថា ភាពស្លូតបូត និងឆន្ទៈដើម្បីជឿលើព្រះបន្ទូលរបស់ព្រះ កើតចេញមកពីភាពទន់ភ្លន់នៃចិត្ត។ វាកើតមកពីការមានដួងចិត្តដែលទទួលយកព្រះវិញ្ញាណបរិសុទ្ធ។ វាកើតមកពីការមានដួងចិត្តដែលអាចស្រឡាញ់។ វាកើតមកពីការមានដួងចិត្ត ដែលនឹងធ្វើ និងរក្សាសេចក្ដីសញ្ញាដ៏ពិសិដ្ឋទាំងឡាយ។ វាកើតមកពីដួងចិត្តទន់ភ្លន់ ដែលអាចទទួលដឹងនូវព្រះចេស្ដានៃដង្វាយធួនរបស់ព្រះគ្រីស្ទ។

ភាពស្លូតបូតដើម្បីជឿនេះ កើតមកពីគំរូរបស់អ្នកដទៃ ដែលមានដួងចិត្តទន់ភ្លន់ ហើយមនុស្សដែលធ្វើជាគំរូភាពស្លូតបូត ដើម្បីជឿនេះ មានដូចជានីហ្វៃ និងលីហៃ។ ឪពុករបស់ពួកគេហេលេមិន បានដាក់ឈ្មោះពួកគេថា នីហ្វៃ និងលីហៃ គឺដើម្បីរំលឹកពួកគេអំពីសេចក្ដីជំនឿរបស់ជីដូនជីតាពួកគេ (សូមមើល ហេលេមិន 5:6)។ ផងដែរ ពួកយើងភាគច្រើន បានបង្កប់នៅក្នុងឈ្មោះរបស់យើងនូវកេរមរតកនៃសេចក្ដីជំនឿមកពីជីដូនជីតា ដែលមានដួងចិត្តទន់ភ្លន់ ហើយរកឃើញ ថាមានភាពងាយស្រួលដើម្បីជឿលើព្រះបន្ទូលរបស់ព្រះ។ ពួកគេមួយចំនួន គឺដូចជាលោកតាលួតរបស់ខ្ញុំ ឈ្មោះ អ៊ីហ្វ្រែម ខេ ហាំង ដែលនៅពេលគាត់បានដឹងថា បងប្រុសរបស់គាត់បាន "ចូលរួមជាមួយពួកមរមន" ត្រូវបានប្ដេជ្ញាចិត្ត ដើម្បីនាំគាត់ត្រឡប់មកផ្ទះវិញ។ មិនគួរឱ្យភ្ញាក់ផ្អើលទេ អ៊ីហ្វ្រែម បានផ្លាស់ទៅណៅវូ ហើយបានទទួលបុណ្យជ្រមុជទឹក ភ្លាម បន្ទាប់ពីគាត់បានឮបងប្រុសរបស់គាត់ ថ្លែងទីបន្ទាល់អំពីយ៉ូសែប ស្ម៊ីធ និងដំណឹងល្អដែលបានស្ដារឡើងវិញ ( សូមមើល Richard K. Hanks *Eph Hanks, Pioneer Scout* និក្ខេបបទដើមដែលបានបង្ហាញទៅកាន់ Department of Church History and Doctrine, Brigham Young University, Richard K. Hanks ឆ្នាំ 1973] ទំព័រ 18--21)។

យើងត្រូវបានប្រទានពរជាមួយនឹងអ្នកដទៃ នៅក្នុងបទគម្ពីរ ដែលបានបង្រៀនយើងអំពីរបៀប ដែលយើងអាចទទួលបានភាពស្លូតបូត និងឆន្ទៈដើម្បីជឿ។ នីហ្វៃ ជាកូនប្រុសរបស់លីហៃ គឺជាគំរូមួយ។ សកម្មភាពដំបូងរបស់គាត់ នៅពេលគាត់បានស្ដាប់

ឮឪពុករបស់គាត់បង្រៀន អំពីការបំផ្លិចបំផ្លាញទីក្រុងយេរូសាឡិម គាត់បានអំពាវនាវទៅដល់ព្រះអម្ចាស់ រហូតដល់ដួងចិត្តរបស់គាត់ ត្រូវបានបន្ទន់ ដើម្បីឱ្យគាត់ជឿនូវពាក្យទាំងអស់ ដែលឪពុករបស់គាត់បាននិយាយ ។ ព្រះអម្ចាស់បាន មានបន្ទូលដោយផ្ទាល់ទៅកាន់នីហ្វៃ "ឱនីហ្វៃអើយ អ្នកមានពរហើយដោយសារសេចក្ដីជំនឿរបស់អ្នក ព្រោះអ្នកបានព្យាយាម ស្វែងរកយើង ដោយមានចិត្តសុភាពរាបសារ" ( នីហ្វៃទី 1 2:20) ។ នីហ្វៃបង្រៀនអំពីសារៈសំខាន់នៃការមានបំណង ប្រាថ្នា និងការព្យាយាមនៅក្នុងការរក្សាបទបញ្ញត្តិទាំងឡាយ ហើយអំពាវនាវដល់ព្រះ ដើម្បីមានលទ្ធផលភាពនិយាយ ដោយងាយថា "ខ្ញុំនឹងទៅធ្វើ" (សូមមើល នីហ្វៃទី 1 3:7) ។

ចេញមកពីគម្ពីរអេណុស យើងបានដឹងអំពីសារៈសំខាន់នៃការអនុញ្ញាតឱ្យបន្ទូលរបស់ព្រះ ចាក់យ៉ាងជ្រៅទៅក្នុងដួងចិត្តរបស់យើង រហូតដល់យើងស្រេកឃ្លានសេចក្ដីពិត (សូមមើល អេណុស 1:3--4) ។ ភាពស្លូតបូតដើម្បីជឿនឹងកើតមាន នៅពេលព្រះបន្ទូលរបស់ព្រះ ត្រូវបានឆ្លាក់ជាប់នៅក្នុងដួងចិត្តរបស់យើង (សូមមើល យេរេមា 31:33, កូរិនថូសទី 2 3:3) ។

ចេញមកពីគំរូនៃបិតារបស់ស្ដេចឡាម៉ូណៃ យើងបានរៀនអំពីសារៈសំខាន់នៃដួងចិត្តទន់ភ្លន់ថា គឺជាការមានឆន្ទៈដើម្បីផ្លាស់ប្ដូរ ។ បិតារបស់ស្ដេចឡាម៉ូណៃ មានឆន្ទៈដើម្បីលះបង់នគរពាក់កណ្ដាល ទៅឱ្យអាំម៉ូន ដើម្បីប្ដូរជីវិតរបស់ទ្រង់ (អាលម៉ា 20:21--23) ។ បន្ទាប់ពីអាំម៉ូនបានស្នើសុំដោយសាមញ្ញថា សុំឱ្យស្ដេចអនុញ្ញាតឱ្យឡាម៉ូណៃបានថ្វាយបង្គំ តាមដែលទ្រង់មានបំណងប្រាថ្នានៅក្នុងនគររបស់ទ្រង់ផ្ទាល់ នោះពាក្យសំដីដោយសេចក្ដីសប្បុរស និងភាពអស្ចារ្យរបស់ អាំម៉ូន បានបណ្ដាលឱ្យស្ដេចកង្វល់ក្នុងព្រះទ័យ និងគំនិត (សូមមើល អាលម៉ា 20:24; 22:3) ។ នៅពេលអើរ៉ុន បាន មកដល់ដើម្បីបង្រៀនស្ដេច នោះដួងចិត្តរបស់ទ្រង់បានផ្លាស់ប្ដូរ ហើយទ្រង់មានភាពស្លូតបូតដើម្បីជឿ នៅពេលទ្រង់មាន បន្ទូលទៅអើរ៉ុនថា "មើលចុះ យើងនឹងជឿ" (អាលម៉ា 22:7) ។ ទ្រង់បានបង្ហាញអំពីឆន្ទៈដើម្បីលះបង់នូវអ្វីៗទាំងអស់ ដែលទ្រង់មាន សូម្បីតែនគររបស់ទ្រង់ ដើម្បីឱ្យមានសេចក្ដីអំណររបស់ព្រះអម្ចាស់ (សូមមើល អាលម៉ា 22:15) ។ នៅ ពេលទ្រង់អធិស្ឋានជាលើកដំបូង ទ្រង់បានថ្វាយនូវអ្វីដែលព្រះវរបិតាសួគ៌ចង់បាន នៅពេលទ្រង់មានបន្ទូលថា "ទូលបង្គំ នឹងបោះបង់ចោលអស់ទាំងអំពើបាបរបស់ទូលបង្គំ ដើម្បីឱ្យបានស្គាល់ទ្រង់" (អាលម៉ា 22:18) ។ ភាពស្លូតបូត និងឆន្ទៈ ដើម្បីជឿលើព្រះបន្ទូលរបស់ព្រះ នឹងកើតមានមកពីការប្រែចិត្ត និងការគោរពប្រតិបត្តិ ។

ការប្រឡងនៅក្នុងជីវិតរបស់យើង នឹងបើកសម្ដែងនូវពេលវេលាដែលយើងរកឃើញថាមានភាពកាន់តែស្លូតបូត ដើម្បីជឿទៅលើព្រះបន្ទូលរបស់ព្រះ ។ ពេលវេលានៃការផ្លាស់ប្ដូរសំខាន់ ដូចជាអាពាហ៍ពិពាហ៍ ឬកំណើតរបស់ទារកម្នាក់ ពេលវេលានៃការបំរើដ៏ខ្លាំងក្លា ដោយសារតែការហៅបំរើថ្មី ឬបេសកកម្មមួយ ពេលវេលានៅក្នុងយុវវ័យរបស់យើង ជាមួយ នឹងប៊ីស្សពដ៏ល្អ អ្នកដឹកនាំយុវវ័យ និងគ្រូបង្រៀនថ្នាក់សិក្ខាសាលា ពេលវេលានៃការសាកល្បង ពេលវេលារីកចំរើន មកពីការរៀនសូត្រសំរាប់គ្រាដំបូងអំពីដំណឹងល្អ ទាំងនេះគឺជាពេលវេលានៃភាពស្លូតបូតដើម្បីជឿ ។ ប្រហែលជាពេល វេលាដ៏សំខាន់បំផុត គឺពេលនៅពីកុមារភាព ។ កាលពីនៅក្មេង ខ្ញុំបានរកឃើញថាវាមានភាពងាយស្រួល ដើម្បីជឿលើ ព្រះបន្ទូលរបស់ព្រះ បានបង្រៀនដល់ខ្ញុំដោយឪពុកម្ដាយ និងជីដូនជីតាដ៏អង់អាចរបស់ខ្ញុំ ។ យើងគ្មាន ការងឿងឆ្ងល់ទេ ដែលយើងត្រូវបានដាស់តឿនដើម្បីឱ្យក្លាយដូចជាកូនក្មេងតូច ដើម្បី

គ្រងជីវិតដ៏អស់កល្បជានិច្ច (សូម មើល នីហ្វៃទី 3 11:38)។ យើងគ្មានការងឿងឆ្ងល់ទេ ដែលយើងត្រូវបានបង្រៀនឱ្យចិញ្ចឹមកូនចៅ [របស់យើង] នៅក្នុង ពន្លឺ និងសេចក្ដីពិត (គ. និង ស. 93:40)។

បើអ្នកដូចខ្ញុំ អ្នកនឹងរកឃើញថា អ្វីដែលពិតជាបាននាំមកនូវភាពស្លូតបូត និងឆន្ទៈដើម្បីជឿ គឺមិនមែនជាកាលៈទេសៈ នោះទេ តែជាការប្ដេជ្ញាចិត្តដើម្បីរស់នៅតាមដំណឹងល្អ អំឡុងពេលនៃជីវិតនេះ។ អ្នកនឹងបានឃើញជាញឹកញាប់ថា អ្នកលុតជង្គង់ចុះ និងសិក្សាព្រះគម្ពីរដោយហ្មត់ចត់នៅក្នុងអំឡុងពេលនេះ។ អ្នកនឹងបានឃើញថា វាកាន់តែងាយស្រួល ដើម្បីប្រមូលគ្នាសំរាប់រាត្រីជួបជុំក្រុមគ្រួសារ និងការអធិស្ឋានជាគ្រួសារ។ អ្នកនឹងបានឃើញថា វាកាន់តែងាយស្រួល ដើម្បីនៅព្រះវិហារ ហើយថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធ។ អ្នកនឹងបានឃើញកាន់តែងាយស្រួលដើម្បីបង់ដង្វាយ មួយភាគក្នុងដប់ និងដង្វាយតមអាហារ។ ជាក់ស្ដែងការរស់នៅតាមដំណឹងល្អប្រចាំថ្ងៃ នាំមកនូវភាពទន់ភ្លន់ក្នុងដួងចិត្ត ដែលចាំបាច់ត្រូវមានភាពស្លូតបូត និងឆន្ទៈដើម្បីជឿលើព្រះបន្ទូលរបស់ព្រះអម្ចាស់។

ទីបន្ទាល់របស់ខ្ញុំ គឺថា ការបង្រៀនមកពីពួកព្យាការីរបស់យើង និងពួកសាវកនៅក្នុងសន្និសីទនេះ បើសិនជាអ្នកធ្វើតាម នោះនឹងនាំឱ្យមានភាពស្លូតបូត និងឆន្ទៈដើម្បីជឿលើព្រះបន្ទូលរបស់ព្រះ។ យើងត្រូវបានប្រឹក្សាឱ្យថ្វាយបង្គំនៅក្នុង ព្រះវិហារ បរិសុទ្ធ ដើម្បីពង្រឹងក្រុមគ្រួសារតាមរយៈការអធិស្ឋានជាគ្រួសារ ការសិក្សាព្រះគម្ពីរ និងរាត្រីជួបជុំក្រុមគ្រួសារ ដើម្បីបំរើដោយឧស្សាហ៍ព្យាយាមនៅក្នុងការហៅបព្វជិតភាព និងការហៅក្នុងសាសនាចក្រ ដើម្បីបង់ដង្វាយ មួយភាគក្នុងដប់ និងដង្វាយផ្សេងៗ ដើម្បីមានសេចក្ដីជំនឿ និងដើម្បីអធិស្ឋានសុំការណែនាំ ហើយដើម្បីរស់នៅដោយសក្ដិសមចំពោះភាពជាដៃគូនៃព្រះវិញ្ញាណ-បរិសុទ្ធ។

ជាញឹកញាប់យើងគឺដូចជាណាម៉ាន់ ជាអ្នកកើតឃ្លង់ពួកស៊ីរី ដែលត្រូវបានបញ្ជូនទៅឱ្យព្យាការីនៅអ៊ីស្រាអែល ដើម្បីបានជាសះស្បើយ។ នៅពេលអេលីសេបានបញ្ជូនអ្នកនាំសារម្នាក់ឱ្យទៅណែនាំឱ្យ ណាម៉ាន់ទៅមុជទឹក នៅក្នុងទន្លេយ័រដាន់ប្រាំពីរដង នោះណាម៉ាន់បានចេញទៅដោយកំហឹង។ ដោយអរគុណ គាត់មានអ្នកបំរើម្នាក់ បាននិយាយប្រាប់ថា "បើសិនជាព្យាការីបានប្រាប់ឱ្យលោកធ្វើការអ្វីយ៉ាងធំ នោះតើលោកមិនធ្វើតាមទេឬអី? ចំណង់បើលោកគ្រាន់តែឱ្យទៅមុជទឹកប៉ុណ្ណោះ ដើម្បីឱ្យបានស្អាត" (ពង្សាវតារក្សត្រទី 2 5:13)។

ខ្ញុំធ្វើសាក្សីថា ភាពស្លូតបូត និងឆន្ទៈដើម្បីជឿនេះ នឹងកើតមានមកពីការធ្វើនូវរឿងទាំងឡាយ ដែលហាក់ដូចជា មិនសូវសំខាន់ដែលបានបង្រៀនដល់យើងដដែលៗចាប់តាំងពីយើងនៅយុវវ័យ។ ការគោរពប្រតិបត្តិ នឹងនាំមកនូវ ដួងចិត្តទន់ភ្លន់ ហើយស្លូតបូតដើម្បីជឿទៅលើព្រះបន្ទូលរបស់ព្រះ។ ខ្ញុំថ្លែងជាសាក្សីថា ភាពស្លូតបូតដើម្បីជឿ នឹងនាំមកនូវការចាក់ស្រោចនៃព្រះវិញ្ញាណ។

ការប្រលងដើម្បីវាស់ភាពស្លូតបូត និងឆន្ទៈដើម្បីជឿរបស់យើង អាចកើតមានរាល់សប្ដាហ៍ នៅពេលយើងចូលរួម ការប្រជុំសាក្រាម៉ង់។ នៅក្នុងការប្រជុំនេះ យើងរំលឹកសេចក្ដីសញ្ញាទាំងឡាយ ដោយការបង្ហាញនូវឆន្ទៈរបស់យើង ដើម្បីលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះគ្រីស្ទ ដើម្បីចងចាំទ្រង់ជានិច្ច ហើយរក្សាបទបញ្ញត្តិទាំងឡាយរបស់ ទ្រង់ (សូមមើល គ. និង ស.

20:77)។ នៅពេលយើងអង្គុយនៅក្នុងការប្រជុំសាក្រាម៉ង់ យើងគួរតែរកឃើញថា វាមានការងាយស្រួលដើម្បីធ្វើសេចក្តីសញ្ញាទាំងនេះ ហើយងាយស្រួលដើម្បីស្តាប់ និងរៀនតាមរយៈព្រះវិញ្ញាណបរិសុទ្ធ។

ខ្ញុំមានព្រះវិញ្ញាណនៃព្រះអម្ចាស់ចាក់ស្រោចមកលើខ្ញុំជាយូរអង្វែង ដោយសារតែភាពស្លូតបូត និងឆន្ទៈដើម្បីជឿ ព្រះបន្ទូលរបស់ទ្រង់។ ខ្ញុំមានអារម្មណ៍ថាបទគម្ពីរនេះ បានដាស់ខ្ញុំឱ្យយល់អំពីកាតព្វកិច្ចរបស់ខ្ញុំចំពោះព្រះ ថាខ្ញុំគួរតែ ចុះចូល និងទន់ភ្លន់ រហ័សធ្វើតាម ពោរពេញទៅដោយការអត់ធ្មត់ មានចិត្តព្យាយាមនៅក្នុងការកាន់តាមព្រះបញ្ញត្តិ ទាំងឡាយនៃព្រះឱ្យ បានគ្រប់ពេលវេលា ហើយតែងតែថ្លែងអំណរគុណដល់ព្រះជានិច្ច ចំពោះអ្វីៗដែល [ខ្ញុំ] បានទទួល (សូមមើល អាលម៉ា 7:22--23)។

សូមឱ្យយើងឃើញជានិច្ចថា វាងាយស្រួលដើម្បីជឿលើព្រះបន្ទូលរបស់ទ្រង់។ សូមឱ្យអ្នក និងខ្ញុំប្រកាសដោយ ភាពស្លូតបូតថា ព្រះយេស៊ូវ គឺជាព្រះរាជបុត្រារបស់ព្រះ។ ទ្រង់គឺជាអ្នកគង្វាលរបស់យើង ហើយអ្នកទាំងឡាយណា ដែលស្លូតបូត និងមានឆន្ទៈដើម្បីជឿ នោះនឹងបានស្គាល់សម្លេងរបស់ទ្រង់។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។